# សន្និបាត
# បូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤
# របស់ក្រសួងផែនការ

ថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

បទបង្ហាញ៖ ស្តីពីសមិទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤

របស់អគ្គនាយកដ្ឋានកិច្ចការទូទៅ និង អគ្គាធិការដ្ឋាន

# ផ្នែកទី១

## សមិទ្ធិផលការងារឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤
## របស់អគ្គនាយកដ្ឋានកិច្ចការទូទៅ

# មាតិកា

១. ស្ថានភាពទូទៅ

២. សមិទ្ធិផលការងារឆ្នាំ២០២៣

៣. ទិសដៅការងារឆ្នាំ២០២៤

៤. បញ្ហាប្រឈម

- អគ្គនាយកដ្ឋានកិច្ចការទូទៅបានបង្កើតដោយអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កក្កដា  ឆ្នាំ២០២២។
- អគ្គនាយកដ្ឋានកិច្ចការទូទៅមាននាយកដ្ឋានចំណុះចំនួន ៥ គឺ៖

១. នាយកដ្ឋានរដ្ឋបាលទូទៅ

២. នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

៣. នាយកដ្ឋានបុគ្គលិក

៤. នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៥. នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

# ២. សមិទ្ធិផលការងារឆ្នាំ២០២៣

❖ នៅក្នុងឆ្នាំ២០២៣ អគ្គនាយកដ្ឋានកិច្ចការទូទៅបានសម្រេចការងារសំខាន់ៗ រួមមាន៖

- ចូលរួមអនុវត្ត និងគាំទ្រការងារកែទម្រង់លើវិស័យរដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ
- ដឹកនាំ និងគ្រប់គ្រងការងាររដ្ឋបាល និងសម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ
- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍មូលធនមនុស្សរបស់ក្រសួង
- បានរៀបចំរបាយការណ៍ត្រីមាស ឆមាស ប្រចាំឆ្នាំ២០២៣របស់ក្រសួងផែនការ
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦
- បានធ្វើគម្រោងកម្មវិធីចំណាយថវិកាប្រចាំឆ្នាំ២០២៣
- បានរៀបចំគម្រោងចំណាយថវិកាប្រចាំឆ្នាំ២០២៤
- បានធ្វើលិខិតចំណាយជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងផែនការ ទៅចូលរួមកិច្ចប្រជុំនៅក្រៅប្រទេស

- បានរៀបចំលិខិតស្នើសុំចំណាយ និងអាណត្តិទូទាត់ជូនកម្មវិធីទាំង៤ របស់ក្រសួងផែនការ
- បានរៀបចំលិខិតស្នើសុំចំណាយបម្រើការងារជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣
- បានរៀបចំលិខិតស្នើសុំចំណាយបម្រើការងារអង្កេតសេដ្ឋកិច្ច សង្គមកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣
- បានសម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង
- បានសហការ សម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការទាំងថ្នាក់ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍ
- គ្រប់គ្រង និងចាត់ចែងការងារសង្គមកិច្ចសម្រាប់មន្ត្រីរាជការ
- ស្រាវជ្រាវ ដកស្រង់ ចងក្រង និងផ្សព្វផ្សាយលិខិតគតិយុត្ត សន្ធិសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ និងគ្រប់គ្រងរក្សាលិខិតបទដ្ឋានគតិយុត្តនានាដូចជា សេចក្តីសម្រេច ប្រកាស សារាចរ អនុក្រឹត ព្រះរាជក្រឹត្យ ច្បាប់ និងកិច្ចព្រមព្រៀងផ្សេងៗ

# ៣. ទិសដៅការងារឆ្នាំ២០២៤

❖ អគ្គនាយកដ្ឋានកិច្ចការទូទៅ មានទិសដៅការងារសម្រាប់ឆ្នាំ២០២៤ មានដូចខាងក្រោម៖

- អនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"
- រៀបចំរបាយការណ៍សាច់ប្រាក់តាមខែនីមួយៗប្រចាំឆ្នាំ២០២៤
- តៀមរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៥-២០២៧ និងផែនការថវិកាឆ្នាំ២០២៥
- ត្រៀមរៀបចំកិច្ចព្រមព្រៀងសមទ្ធិកម្មជាពកម្រិត
- បន្តគ្រប់គ្រង និងចាត់ចែងការងារសង្គមកិច្ចសម្រាប់មន្ត្រីរាជការ
- ចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងផែនការទៅបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល និងកន្លែងបណ្តុះបណ្តាលជាច្រើនទៀត
- រៀបចំរបាយការណ៍ត្រីមាស ឆមាស និងប្រចាំឆ្នាំ២០២៤

បានសហការ សម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការទាំងថ្នាក់ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍ

- បន្តសហការប្រមូលធាតុចូលការងារជាមួយបណ្ដាក្រសួង ស្ថាប័ននានា និងអង្គភាពក្រោមចំណុះក្រសួងផែនការ
- រៀបចំវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីក្រសួងផែនការ ស្ដីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាន និងឌីជីថល
- បន្តសហការជាមួយក្រុមហ៊ុនសាងសង់មជ្ឈមណ្ឌលទិន្នន័យ ដើម្បីរៀបចំផ្ទេរទិន្នន័យរបស់អង្គភាពក្រោមចំណុះក្រសួងផែនការ។

# ៤. បញ្ហាប្រឈម

- ទីធ្លាការិយាល័យ មិនទាន់បំពេញបានតាមចំនួនមន្ត្រីជាក់ស្តែង កំពុងបំពេញការងារ
- សម្ភារៈបរិក្ខារការិយាល័យ មានចំនួនកម្រិត
- មូលធនមនុស្ស និងប្រសិទ្ធភាពការងារ នៅមានកម្រិត។



# ផ្នែកទី២

## សមិទ្ធផលការងារឆ្នាំ២០២៣ និង ទិសដៅការងារឆ្នាំ២០២៤ របស់អគ្គាធិការដ្ឋាន

# មាតិកា

១. សេចក្តីផ្តើម

២. សកម្មភាព និងសមិទ្ធិផលការងារសម្រេចបានឆ្នាំ២០២៣

៣. បញ្ហាប្រឈម

៤. សំណូមពរ

៥. ទិសដៅបន្ត

៦. សន្និដ្ឋាន

## I. សេចក្ដីផ្ដើម

ដើម្បីឆ្លើយតបទៅនឹងស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមរបស់សម្ដេចធិបតី ហ៊ុន ម៉ាណែត គឺផ្ដោតលើការកែទម្រង់ ការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឱ្យក្លាយជារដ្ឋបាលសាធារណៈដែលប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ និងស្របតាមពាក្យស្លោករបស់សម្ដេចតេជោ "អធិការកិច្ចជាភ្នែក, ជាត្រចៀក របស់ថ្នាក់លើ និងជាមិត្តដ៏ជិតស្និទ្ធរបស់ថ្នាក់ក្រោម " ដែលពាក្យស្លោកនេះត្រូវបានប្រើប្រាស់ជាបេសកកម្មរបស់អង្គភាព អធិការកិច្ច។

អគ្គាធិការដ្ឋាននៃក្រសួងផែនការ បានបង្កើតឡើង នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ មានមុខងារ និងតួនាទីសិទ្ធិអំណាចរបស់អគ្គាធិការដ្ឋាន ត្រូវបានអនុលោមតាមអនុក្រឹត្យលេខ៥៥ អនក្រ.បកចុះ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ ។

បន្ទាប់មកអគ្គាធិការដ្ឋាន នៃក្រសួងផែនការត្រូវបានធ្វើវិសោធនកម្មបង្កើតបានអនុក្រឹត្យលេខ៧០ អនក្រ.បកចុះ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ នៅឆ្នាំ២០២២ ត្រូវបានធ្វើវិសោធនកម្មម្ដងទៀតបង្កើតបានអនុក្រឹត្យ លេខ១៤៤ អនក្រ.បក ចុះថ្ងៃព្រហស្បតិ៍ ១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ។

**ថ្នាក់ដឹកនាំអគ្គាធិការដ្ឋានមានជាបន្តបន្ទាប់ដូចខាងក្រោម៖**

- ឯកឧត្តម **ប៉ាន់ ណាង** អគ្គាធិការ នៅឆ្នាំ ១៩៩៧ (បច្ចុប្បន្នស្លាប់)
- ឯកឧត្តម **ហ៊ី ហួរ** អគ្គាធិការ មិនចាំឆ្នាំ (បច្ចុប្បន្នស្លាប់)
- ឯកឧត្តម **មូ សុភាព** អគ្គាធិការ នៅឆ្នាំ ២០០៩ដល់ឆ្នាំ២០១៣ ត្រូវបានព្រះរាជក្រឹត្យតែងតាំងជា អនុរដ្ឋលេខាធិការក្រសួងផែនការ (បច្ចុប្បន្នស្លាប់)
- លោកជំទាវ **ជុំ ស៊ីណា** អគ្គាធិការ នៅឆ្នាំ២០១៣ដល់ឆ្នាំ២០១៤ ចូលនិវត្តន៍ត្រូវបានព្រះរាជក្រឹត្យតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងការពារជាតិ
- ឯកឧត្តម **ទ្រី សុធារិទ្ធ** អគ្គាធិការ ឆ្នាំ២០១៤ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ត្រូវបានព្រះរាជក្រឹត្យតែងតាំងជានាយកសាលាជាតិផែនការស្ថិតិ
- ឯកឧត្តម **គីម ប៉េងអ៊ីង** អគ្គាធិការ ត្រូវបានព្រះរាជក្រឹត្យតែងតាំងពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ដល់បច្ចុប្បន្ន។

បច្ចុប្បន្ននេះអគ្គាធិការដ្ឋាន នៃក្រសួងផែនការ មានមុខងារ និងតួនាទីសិទ្ធិអំណាចដោយអនុលោមតាមអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃព្រហស្បតិ៍ ១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ និងប្រកាសលេខ ០០១១ ផក ចុះថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងផ្នែកក្រោមឱវាទក្រសួងផែនការ។

**អគ្គាធិការដ្ឋានរបស់ក្រសួងផែនការទទួលបន្ទុក៖**

១-ទទួលបន្ទុកអនុវត្តមុខងារដូចមានចែងក្នុងអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្ដីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច

២-រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំ និងប្រចាំឆ្នាំរបស់អគ្គាធិការដ្ឋាន

៣- ធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងផែនការ

៤-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ច និងគោលនយោបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

៥- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

## II. សកម្មភាព និងសមិទ្ធផលការងារសម្រេចបាន

ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ អគ្គាធិការដ្ឋានបានអនុវត្ត និងបំពេញការងាររបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានលទ្ធផលដូចខាងក្រោម៖

### ១. ការងារស្នូល

- បានរៀបចំកម្មវិធីធ្វើអធិការកិច្ចដើម្បីវាយតម្លៃលើអភិក្រមហានិភ័យក្នុងការិយបរិច្ឆេទ២០២២ និងបណ្ដាឆ្នាំពាក់ព័ន្ធគ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ
- បានចុះធ្វើអធិការកិច្ចនៅមន្ទីរផែនការខេត្តមួយចំនួនដូចជា ខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តប៉ៃលិន ខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង ខេត្តកែប ខេត្តក្រចេះ ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងមន្ទីរផែនការរាជធានីភ្នំពេញ
- ចូលរួមសន្និបាតបូកសរុបការងារ ឆ្នាំ២០២២ និងទិសដៅ ឆ្នាំ២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ធ្វើរបាយការណ៍សង្ខេបអំពីសមិទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២៣)
- ធ្វើបញ្ជីស្ថិតិមន្ត្រីរាជការតាមកម្រិតសញ្ញាបត្រជូននាយកដ្ឋានបុគ្គលិក
- ធ្វើបច្ចុប្បន្នភាពបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គាធិការដ្ឋាន និងកែសម្រួលរចនាសម្ព័ន្ធ

- ប្រជុំត្រួតពិនិត្យលើប្រព័ន្ធការងារអធិការកិច្ច
- បានធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំនព្វមាស
- ធ្វើបទបង្ហាញចែករំលែកស្តីពីមេរៀនអធិការកិច្ចសង្ខេប ដល់មន្ត្រីអគ្គាធិការដ្ឋានចំនួន២លើក
- អគ្គាធិការដ្ឋាន បានទទួលរថយន្តមួយគ្រឿង សម្រាប់ចុះធ្វើអធិការកិច្ច
- អគ្គាធិការដ្ឋានបានធ្វើការប្រជុំស្តីពីកិច្ចការទូទៅរវាងថ្នាក់ដឹកនាំ និងមន្ត្រីអគ្គាធិការដ្ឋានក្រោមអធិបតីភាព **លោកជំទាវ ផុង សារុន** រដ្ឋលេខាធិការទទួលបន្ទុកជួយសម្របសម្រួលអគ្គាធិការដ្ឋាន និង **ឯកឧត្តម ពេជ្រ បួងឃាង** អនុរដ្ឋលេខាធិការទទួលបន្ទុកជួយសម្របសម្រួលចង្កោមការងារ លោកជំទាវរដ្ឋលេខាធិការ
- កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ អគ្គាធិការដ្ឋាន បានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ** ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីអគ្គាធិការដ្ឋានទាំងអស់ ស្តីអំពីវឌ្ឍនភាពការងារ ណែនាំរបៀបរបបការងារ បញ្ហាប្រឈម និងដាក់ទិសដៅការងារបន្ត
- អគ្គាធិការដ្ឋានបានគ្រោងរៀបចំគម្រោងថវិកាកម្មវិធីឆ្នាំ២០២៥
- ចូលរួមពិធីប្រកាសចូលកាន់មុខតំណែង អគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិ និងអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងផែនការកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣
- ចូលរួមប្រជុំកំណែទំរង់រដ្ឋបាលសាធារណៈ ១៣ ធ្នូ ឆ្នាំ២០២៣។

## ២. ការងាររដ្ឋបាល

- ឯកសារចូលបានទទួលសរុបចំនួន ២២ករណី
- ឯកសារដែលបានចេញសរុបចំនួន ១០២ករណី

## ៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៣.១. ការគ្រប់គ្រងមន្ត្រីរាជការ

គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អគ្គាធិការដ្ឋានមានមន្ត្រីសរុបទាំងអស់ចំនួន ៧១ នាក់ មានស្រីចំនួន ២៩ នាក់ ក្នុងនោះរួមមាន៖

- អគ្គាធិការមាន ១ នាក់
- អគ្គាធិការរងមាន ២០ នាក់ ស្រី ៨ នាក់
- អធិការមាន ២៤ នាក់ ស្រី ៧ នាក់
- អនុប្រធានការិយាល័យ ១ នាក់ ស្រី ១ នាក់
- មន្ត្រីមាន ២៥ នាក់ ស្រី ១៣ នាក់។
- រៀបចំបញ្ជីវត្តមានមន្ត្រីរាជការប្រចាំថ្ងៃ បូកសរុបសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ

## ៣.២. គុណវុឌ្ឍន៍មន្ត្រីរាជការក្នុងអគ្គាធិការដ្ឋាន

| តួនាទី | ចំនួនមន្ត្រីរាជការ | | កម្រិតវប្បធម៌ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | បណ្ឌិត | អនុបណ្ឌិត | បរិញ្ញាបត្រ | ទុតិយភូមិ | |
| អគ្គាធិការរង | ២០ | ៨ | - | ១២ | ៨ | | |
| អធិការ | ២៤ | ៧ | - | ៨ | ១៦ | | |
| មន្ត្រី | ២៦ | ១៤ | - | ១ | ២៤ | ១ | |
| **សរុបរួម** | ៧០ | ២៩ | - | ២១ | ៤៨ | ១ | |

## ៣.៣. ប្រភេទកាំប្រាក់

| តួនាទី | ប្រភេទកាំប្រាក់ | | | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | ក១ | ក២ | ក៣ | ខ១ | ខ២ | ខ៣ | គ៥ | គ៩ | |
| អគ្គាធិការរង | ១៣ | ៦ | ១ | - | - | - | - | - | |
| អធិការ | ៣ | ១០ | ១១ | - | - | - | - | - | |
| មន្ត្រី | - | ១ | ២០ | - | - | ២ | ១ | ១ | |
| **សរុបរួម** | ១៦ | ១៧ | ៣២ | - | - | ២ | ១ | ១ | |

## III. បញ្ហាប្រឈម

- អគ្គាធិការដ្ឋានពុំទាន់មានរចនាសម្ព័ន្ធរដ្ឋបាលច្បាស់លាស់
- សមត្ថភាពមន្ត្រីក្នុងអគ្គាធិការដ្ឋាននៅមានកម្រិត
- ពុំទាន់មានដៃគូអភិវឌ្ឍជាតិ និងអន្តជាតិជួយគាំទ្រលើវិស័យអធិការកិច្ចបានទូលំទូលាយ។

## IV. សំណូមពរ

- ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីមេត្តាជួយពន្លឿនឱ្យបានឆាប់ចេញនូវរចនាសម្ព័ន្ធថ្មីរបស់អគ្គាធិការដ្ឋាន
- ជួយផ្តល់គ្រូបង្ហាត់បង្រៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច សម្រាប់មន្ត្រីមកដល់ទីកន្លែងអគ្គាធិការដ្ឋាន ក្រសួងផែនការ ឬផ្តល់ឱ្យមន្ត្រីអគ្គាធិការដ្ឋាន ក្រសួងផែនការបានចំនួនមន្ត្រីច្រើនជាងវគ្គមុនៗ ទៅចូលរួមរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច នៅវិទ្យាស្ថានជាតិអធិការកិច្ចនៃក្រសួងអធិការកិច្ច
- ជួយធ្វើការទំនាក់ទំនងមានដៃគូអភិវឌ្ឍជាតិ និងអន្តជាតិគាំទ្រលើវិស័យអធិការកិច្ចនៅអគ្គាធិការដ្ឋាននៃក្រសួងផែនការឱ្យបានទូលំទូលាយ។

## V. ទិសដៅការងារបន្ត

- បន្តរៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ឱ្យកាន់តែល្អប្រសើរឡើង
- បន្តការងារធ្វើអធិការកិច្ច នៅតាមបណ្តាមន្ទីរផែនការរាជធានីខេត្តនៅក្នុងឆ្នាំ២០២៤
- បន្តចុះធ្វើវេទិការសាធារណៈតាមការរៀបចំរបស់រាជរដ្ឋាភិបាល
- បន្តពង្រឹងការងារបច្ចេកទេស និងការងារគ្រប់គ្រងរបស់អគ្គាធិការដ្ឋាន
- ប្រជុំពិភាក្សារៀបចំរបាយការណ៍គំរូសម្រាប់ចុះអធិការកិច្ចតាមអង្គភាពក្រោមឱវាទក្រសួងផែនការ
- បន្តរៀបចំយុទ្ធសាស្ត្រ និងយុទ្ធវិធីក្នុងការធ្វើអធិការកិច្ចទៅតាមបណ្តាអង្គភាពថ្នាក់ក្រោមជាតិ
- រៀបចំយុទ្ធសាស្ត្រ និងយុទ្ធវិធីក្នុងការធ្វើអធិការកិច្ចទៅតាមបណ្តាអង្គភាពថ្នាក់ជាតិ
- រៀបចំចងក្រង និងសិក្សាស្រាវជ្រាវឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗបន្ថែមទៀត ពាក់ព័ន្ធការងារអធិការកិច្ច
- រៀបចំផែនការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការក្នុងអគ្គាធិការដ្ឋានពាក់ព័ន្ធទៅនឹងការងារធ្វើអធិការកិច្ច
- រៀបចំធ្វើផែនការ និងសុំគោលការណ៍ចុះធ្វើអធិការកិច្ចសម្រាប់ឆ្នាំ២០២៤ បន្ត
- រៀបចំរចនាសម្ព័ន្ធថ្មីសម្រាប់អគ្គាធិការដ្ឋានដើម្បីធ្វើប្រតិភូកម្មការងារទៅតាមនាយកដ្ឋាន និងការិយាល័យ ដូចមានរចនាសម្ព័ន្ធជូនភ្ជាប់។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## ពង្រាងរចនាសម្ព័ន្ធ អគ្គាធិការដ្ឋាននៃក្រសួងផែនការ

### អគ្គាធិការដ្ឋាន

- **លេខាធិការដ្ឋាន**
  - ការិយាល័យ រដ្ឋបាលសរុប
  - ការិយាល័យ បុគ្គលិក និង ធនធានមនុស្ស
  - ការិយាល័យ ទិន្នន័យ និងព័ត៌មានវិទ្យា
  - ការិយាល័យ ផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
- **នាយកដ្ឋានអធិការកិច្ច**
  - ការិយាល័យ រដ្ឋបាល
  - ការិយាល័យអធិការកិច្ច អង្គភាពថ្នាក់ជាតិ
  - ការិយាល័យអធិការកិច្ច អង្គភាពថ្នាក់ក្រោមជាតិ
  - ការិយាល័យតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គម្រោង
- **នាយកដ្ឋានទទួលពាក្យបណ្ដឹង និង ចាត់ការពាក្យបណ្ដឹង**
  - ការិយាល័យ រដ្ឋបាល និង ទទួលពាក្យបណ្ដឹង
  - ការិយាល័យ អង្កេតស្រាវជ្រាវ ពាក្យបណ្ដឹង
- **នាយកដ្ឋានស្រាវជ្រាវ និងទំនាក់ទំនង**
  - ការិយាល័យ រដ្ឋបាល
  - ការិយាល័យ ស្រាវជ្រាវច្បាប់ និង ផ្សព្វផ្សាយ
  - ការិយាល័យ ទំនាក់ទំនង និង សហប្រតិបត្តិការ

## VI. សន្និដ្ឋាន

ដោយគោរពទៅតាមតួនាទី និងភារកិច្ចដែលមានចែងក្នុងអនុក្រឹត្យ និងឯកសារគតិយុត្តិផ្សេងៗ ថ្នាក់ដឹកនាំ និងមន្ត្រីនៅអគ្គាធិការដ្ឋានបានខិតខំប្រឹងប្រែងបំពេញភារកិច្ចទៅតាមតួនាទីរបស់ខ្លួន បើទោះជាជួបបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាសន្និដ្ឋានរួមថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គាធិការដ្ឋានបានសហការគ្នាក្នុងការបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព និងរលូន។

# សូមអរគុណ